ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

លេខ: 0061/0416

# សារលិខិតជូនពរ
## ឯកឧត្តម ជា សុផារ៉ា
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក អដ្ឋស័ក ព.ស២៥៦០

***ឯកឧត្តម ទេសរដ្ឋមន្ត្រី ជាទីគោរព !***

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយមនោសញ្ចេតនា អភិរម្យសោមនស្សរីករាយនៃឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក អដ្ឋស័ក ព.ស២៥៦០ និង អបអរសាទរចំពោះ **ឯកឧត្តម** ដែលត្រូវបានប្រមុខរាជរដ្ឋាភិបាលតែងតាំង ជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខ្ញុំបាទ និងភរិយា រួមទាំងថ្នាក់ដឹកនាំ និងសមាជិក-សមាជិកានៃសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា សូមចូលរួមគោរពជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សេរីវឌ្ឍនា វិបុលសុខ មហាប្រសើរចំពោះ **ឯកឧត្តម** ឲ្យប្រកបដោយសុខភាពល្អបរិបូណ៌ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ ដើម្បីសម្រេចនូវភារកិច្ចដ៏ឧដុង្គឧត្តម ចំពោះជាតិនិងប្រជាជនកម្ពុជាជាទីស្នេហានៃយើងទទួលបានជោគជ័យ និងនាំមកនូវសមិទ្ធិផលធំធេងបន្តទៀត ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពសម្តែងនូវការដឹងគុណចំពោះ **ឯកឧត្តម** ដែលឯកឧត្តមមានគុណបំណាច់ដ៏ឧដុង្គឧត្តមចំពោះជាតិ និងប្រជាជន។ **ឯកឧត្តម** ព្រមទាំងបានរួមចំណែកដ៏ថ្លៃថ្លានៅក្នុងស្ថាប័នរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយមគ្គុទ្ទេសក៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងបុព្វហេតុធ្វើឲ្យជាតិមាតុភូមិជាទីស្នេហាមានសុខសន្តិភាព វិបុលភាព វឌ្ឍនភាពជាតិលើគ្រប់វិស័យ ព្រមទាំងរក្សាការពារបាននូវឯករាជ្យជាតិ អធិបតេយ្យភាពជាតិ និង បូរណភាពទឹកដីកម្ពុជាជាទីស្នេហានៃយើង។

ក្នុងឱកាសដ៏នក្ខត្តឫក្សនេះ ខ្ញុំយើងខ្ញុំទាំងអស់គ្នា សូមគោរពជូនពរបវរមហាប្រសើរដល់ **ឯកឧត្តម** និង **លោកជំទាវ** ប្រកបដោយសុខភាពមាំមួនប្រាជ្ញាភ្លឺថ្លា ដើម្បី **ឯកឧត្តម** សម្រេចនូវភារកិច្ចដ៏ឧដុង្គឧត្តម រួមចំណែកដឹកនាំកម្ពុជាឲ្យបន្តមានសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរពអំពីយើងខ្ញុំទាំងអស់គ្នា៕

*រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦*

**អគ្គនាយក ក្រុមហ៊ុនលីហួរគ្រុប**
**និងប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា**

**ឧកញ៉ា លី ហួរ**

ទីស្នាក់ការ: អគារលេខ 85-88 មហាវិថី គីមអ៊ីលស៊ុល(289)សង្កាត់ បឹងកក់2 ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (855)85 500 555 Email: hda.cambodia@gmail.com